ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

*ថ្ងៃ អង្គារ ០៣ រោច ខែ កត្តិក ឆ្នាំជូត ទោស័ក ព.ស ២៥៦៤*
*រាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ២០២០*

## សេចក្តីប្រកាសព័ត៌មាន
## ស្តីពី
## ជំនួបពិភាក្សាការងាររវាងឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ជាមួយនិងឯកឧត្តម Anatoly Borovik ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសហព័ន្ធរុស្ស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា

នារសៀលថ្ងៃទី ០៣ ខែ វិច្ឆិកា ឆ្នាំ ២០២០, នៅទីស្តីការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានទទួលជួបពិភាក្សាការងារ ជាមួយឯកឧត្តម Anatoly Borovik ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាពនៃសហព័ន្ធរុស្ស៊ីប្រចាំព្រះរាជាណាចក្រកម្ពុជា នាឱកាសដែលឯកឧត្តមទើបចូលកាន់តំណែង ដើម្បីបន្តពង្រឹងបន្ថែមទៀតនូវកិច្ចសហប្រតិបត្តិការទ្វេភាគីកម្ពុជា-រុស្ស៊ី ។

ជាមួយនឹងកិច្ចស្វាគមន៍យ៉ាងកក់ក្តៅជូនចំពោះឯកឧត្តម Anatoly Borovik ដែលទើបត្រូវបានរដ្ឋាភិបាលសហព័ន្ធរុស្ស៊ីតែងតាំងជាឯកអគ្គរដ្ឋទូតប្រចាំព្រះរាជាណាចក្រកម្ពុជា, ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី បានគូសបញ្ជាក់ថា រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជាចងចាំមិនភ្លេច និងថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរដ្ឋាភិបាល និងប្រជាជនរុស្ស៊ី ដែលបានជួយឧបត្ថម្ភគាំទ្រដ៏ថ្លៃថ្លាក្នុងពេលដែលប្រទេសកម្ពុជាកំពុងជួបការលំបាកកាលពីទសវត្សទី ៨០ បន្ទាប់ពីប្រទេសជាតិត្រូវបានរំដោះចេញពីរបបប្រល័យពូជសាសន៍ និងរងការហ៊ុំព័ទ្ធសេដ្ឋកិច្ចយ៉ាងអយុត្តិធម៌ ។ កាលនោះ អតីតសហភាពសូវៀតបានផ្តល់ជំនួយមនុស្សធម៌យ៉ាងច្រើនដល់កម្ពុជា និងបានចូលរួមចំណែកយ៉ាងសកម្មក្នុងដំណើរការកសាងសន្តិភាព និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ជាពិសេស ក្នុងវិស័យ អប់រំ និងសុខាភិបាល ។ ធនធានមនុស្ស បច្ចេកវិទ្យា និងសំណង់ហេដ្ឋារចនាសម្ព័ន្ធនានា ដែលប្រសូត្រចេញពីចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ កម្ពុជា និងរុស្ស៊ី បាននិងកំពុងផ្តល់លទ្ធផលប្រកបដោយផ្លែផ្កា ។

ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** បានជម្រាបឯកឧត្តមឯកអគ្គរដ្ឋទូតរុស្ស៊ី Anatoly Borovik ដែរថា បើទោះបីជាស្ថិតក្នុងបរិការណ៍វិបត្តិនៃជំងឺកូវីដ-១៩ ក៏ដោយ ក៏កិច្ចសហប្រតិបត្តិការរវាងប្រទេសទាំងពីរ កម្ពុជា-រុស្ស៊ី នៅតែដំណើរការទៅមុខដោយរលូន ជាពិសេស ក្នុងវិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម វិនិយោគ អប់រំ សុខាភិបាល និងវប្បធម៌ ។ រាជរដ្ឋាភិបាលកម្ពុជា ត្រៀមខ្លួនជាស្រេចក្នុងការជំរុញកិច្ចសហប្រតិបត្តិការទាំងនេះឱ្យកាន់តែសកម្មថែមទៀត ។ ជាមួយគ្នានេះ, រាជរដ្ឋាភិបាលកម្ពុជាស្វាគមន៍វិនិយោគិនពីរុស្ស៊ីមកដាក់ទុនវិនិយោគបន្ថែមទៀតនៅកម្ពុជា ដើម្បីបង្កើនទំហំពាណិជ្ជកម្មទ្វេភាគី និងជំរុញកំណើនសេដ្ឋកិច្ច ។

ឯកឧត្តមឯកអគ្គរដ្ឋទូតរុស្ស៊ី Anatoly Borovik បានគូសបញ្ជាក់ថា រដ្ឋាភិបាលសហព័ន្ធរុស្ស៊ី នឹងបន្តជួយដល់រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា ជាពិសេស ក្នុងវិស័យអប់រំ និងសុខាភិបាល ដូចជា ការផ្តល់អាហារូបករណ៍ដល់និស្សិតកម្ពុជាទៅសិក្សានៅសហព័ន្ធរុស្ស៊ី ការបណ្តុះបណ្តាលជំនាញ និងជំនួយបច្ចេកទេស ជាដើម ។ ឯកឧត្តមឯកអគ្គរដ្ឋទូតបានវាយតម្លៃខ្ពស់ចំពោះរាជរដ្ឋាភិបាលកម្ពុជាដែលបានចាត់វិធានការត្រឹមត្រូវ និងទាន់ពេលវេលា ក្នុងការប្រយុទ្ធប្រឆាំងនឹងជំងឺកូវីដ-១៩ ដោយរក្សាបាននូវស្ថិរភាពសេដ្ឋកិច្ច និងសង្គម ហើយគ្រប់គ្រងការឆ្លងរាលដាលនៃជំងឺរាតត្បាតនេះបានយ៉ាងល្អប្រសើរ ។

ជាមួយគ្នានេះ, ឯកឧត្តម Anatoly Borovik ក៏បានជម្រាបផងដែរថា ដោយមើលឃើញពីសក្តានុពលនៃប្រទេសកម្ពុជា មានក្រុមហ៊ុនរុស្ស៊ីជាច្រើន ទាំងក្រុមហ៊ុនធំ និងមធ្យម កំពុងមានចំណាប់អារម្មណ៍ និងស្វែងរកកាលានុវត្តភាព ក្នុងការដាក់ទុនវិនិយោគ និងប្រកបធុរកិច្ចនៅកម្ពុជា ។ ក្នុងន័យនេះ, ឯកឧត្តមឯកអគ្គរដ្ឋទូតជឿជាក់ថា នាពេលខាងមុខ ទំហំពាណិជ្ជកម្មទ្វេភាគីរវាងប្រទេសទាំងពីរនឹងមានការកើនឡើងជាបន្តបន្ទាប់ ។

ជាទីបញ្ចប់ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី បានជូនពរឯកឧត្តម Anatoly Borovik សូមបំពេញបេសកកម្មការទូតនៅកម្ពុជាប្រកបដោយជោគជ័យ ។